01721091

F71/1/1/8

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2023, 15:22
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS (បម្រុង)

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Falguni DEBNATH

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

## I. ប្រវត្តិនីតិវិធី

1. ដោយអនុលោមតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានដែលពាក់ព័ន្ធ (វិសោធនកម្មលើកទីមួយ) ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ") អង្គជំនុំជម្រះតុលាការកំពូលដែលជាការិយាល័យតុលាការចុងក្រោយក្នុងការទទួលសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ("សំណុំរឿង ០០២") បានចាប់ផ្តើមធ្វើការពិនិត្យឡើងវិញលើឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងនេះសម្រាប់គោលបំណងធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។

2. នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការគូសបង្ហាញសេចក្តីណែនាំដែលត្រូវបានស្នើឡើងសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងបានអញ្ជើញគ្រប់ភាគី អង្គជំនុំជម្រះ និងអង្គភាពនានានៃ អ.វ.ត.ក. ឱ្យផ្តល់យោបល់ត្រឹមថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានអនុម័តសេចក្តីណែនាំចុងក្រោយដែលនឹងត្រូវអនុវត្តតាមក្នុងការពិនិត្យលើការធ្វើចំណាត់ថ្នាក់ឯកសារទាំងអស់ក្នុងសំណុំរឿង ០០២។ ដើម្បីពិចារណាឱ្យបានសមស្របទៅលើមូលហេតុដែលតម្រូវឱ្យដាក់ចំណាត់ថ្នាក់ឯកសារពីដំបូងថា ជាសម្ងាត់ ឬសម្ងាត់បំផុត អង្គជំនុំជម្រះបានពិនិត្យដោយប្រុងប្រយ័ត្នលើសារណាភាគី អង្គជំនុំជម្រះ និងអង្គភាពពាក់ព័ន្ធនៃ អ.វ.ត.ក. ជាពិសេសការិយាល័យតុលាការដែលបានសម្រេចពីដំបូងដាក់ចំណាត់ថ្នាក់ឯកសារនោះ និងបានពិចារណាលើមូលហេតុធៀបនឹងការបង្ហាញជាសាធារណៈនូវឯកសារមួយចំនួន ឬប្រភេទឯកសារដែលនៅតែសម្ងាត់រហូតដល់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។

## II. ការសង្កេតរបស់ភាគី

3. ភាគី អង្គជំនុំជម្រះ និងអង្គភាពនៃ អ.វ.ត.ក. ដែលបានដាក់សេចក្តីសង្កេតរបស់ខ្លួនស្តីពីសេចក្តីណែនាំដែលត្រូវបានស្នើឡើងនេះ ជាទូទៅបានគាំទ្រដល់ការបង្ហាញជាសាធារណៈ និងស្របជាមួយនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះ និងការសន្មតស្តីពីការបង្ហាញជាសាធារណៈនូវឯកសារក្នុងសំណុំរឿង

០០២ លើកលែងតែភាពចាំបាច់ក្នុងការការពារអត្ថប្រយោជន៍ផ្សេងៗ ដូចជាសន្តិសុខ និងភាពឯកជនរបស់បុគ្គល ទើបឯកសារទាំងនោះតម្រូវឱ្យរក្សាទុកជាសម្ងាត់ ឬសម្ងាត់បំផុត[1]។

4. មេធាវីការពារក្តី ខៀវ សំផន ដែលត្រូវបានគាំទ្រដោយអង្គភាពគាំការការពារក្តី[2]បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការគោរពភាពឯកជនរបស់អ្នកដែលពុំត្រូវបានជ្រើសរើសធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី និងរក្សាការសម្ងាត់បំផុតនូវឯកសារដែលពាក់ព័ន្ធទៅនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក. *ឧ.* វិញ្ញាបនបត្រវេជ្ជសាស្ត្រ មតិរបស់អ្នកជំនាញ របាយការណ៍សម្រាកព្យាបាលនៅមន្ទីរពេទ្យ និងឯកសារផ្សេងទៀតដែលបានចេញដោយអង្គភាពវេជ្ជសាស្ត្រនានា[3]។

5. ក្នុងការឆ្លើយតបទៅនឹងសេចក្តីណែនាំដែលបានស្នើឡើងនោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") បានផ្តល់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ព្រមទាំងវិធានការការពារដែលត្រូវបានបង្គាប់សម្រាប់ការផ្តល់សក្ខីកម្មរបស់ពួកគេ[4]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឈ្មោះសម្គាល់ចំពោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលបានផ្តល់សក្ខីកម្មជាសាធារណៈនៅក្នុងសាលក្រមរបស់ខ្លួន (E313 និង E465) និងសេចក្តីសម្រេចស្តីពីសាក្សី (E312 និង E459)។ បើតាមអ្វីដែលអង្គភាព

[1] សេចក្តីសង្កេតរបស់សហមេធាវីការពារក្តីលើអនុស្សរណៈរបស់លោកប្រធានអង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២ ឯកសារលេខ F71/1/1/5 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ("សេចក្តីសង្កេតរបស់មេធាវីការពារក្តី (F71/1/1/5)") កថាខណ្ឌ ៤-៦។ សេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាលស្តីពីសំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ឯកសារលេខ F71/1/1/2 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល (F71/1/1/2)") កថាខណ្ឌ ២។ ការឆ្លើយតបទៅនឹងការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូល"លើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" ឯកសារលេខ F71/1/1/6 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់អង្គភាពគាំពារការការពារក្តី (F71/1/1/6)") កថាខណ្ឌ ២។ ការឆ្លើយតបទៅនឹងការពិនិត្យរបស់អង្គជំនុំជម្រះតុលាការកំពូល"លើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" ឯកសារលេខ F71/1/1/3 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់សហមេធាវីនាំមុខ (F71/1/1/3)")។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូលដាក់សារណាពាក់ព័ន្ធទៅនឹងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ឯកសារលេខ F71/1/1/4 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4)")។

[2] ការឆ្លើយតបរបស់អង្គភាពគាំពារការការពារក្តី (F71/1/1/6) កថាខណ្ឌ ២។

[3] សេចក្តីសង្កេតរបស់មេធាវីការពារក្តី (F71/1/1/5) កថាខណ្ឌ ៦-៨។

[4] អនុស្សរណៈអន្តរការិយាល័យរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ F71/1/1/7 ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (F71/1/1/7)") ទំព័រ ១។

គាំពារសាក្សី និងអ្នកជំនាញបានដឹង វិធានការការពារផ្សេងទៀតដូចជា ការបំប្លែងសំឡេង និងបិទបាំងមុខ នៅតែមានអត្ថិភាពនៅឡើយសម្រាប់សាក្សីដែលបានបង្ហាញអត្តសញ្ញាណ[5]។

6. ការិយាល័យរដ្ឋបាលផ្តល់អនុសាសន៍ថា ប្រភេទឯកសារខាងក្រោមគប្បីត្រូវបានពិនិត្យសម្រាប់លទ្ធភាពធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ[6]៖

ក) ឯកសារសម្ងាត់ក្នុងសំណុំរឿង ០០២ ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈក្នុងសំណុំរឿងដទៃទៀត៖ ពាក់ព័ន្ធបញ្ហានេះ ការិយាល័យរដ្ឋបាលបានភ្ជាប់បញ្ជីឯកសារសម្ងាត់ដែលត្រូវបានបង្ហាញជាសាធារណៈក្នុងសំណុំរឿងដទៃទៀត (ឧបសម្ព័ន្ធ ក)[7]។

ខ) សំណុំរឿងពិសេសដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២៖ ការិយាល័យរដ្ឋបាលបានភ្ជាប់បញ្ជីសំណុំរឿងពិសេសពាក់ព័ន្ធបញ្ហានេះ (ឧបសម្ព័ន្ធ ខ)[8]។

គ) ភស្តុតាងទាំងអស់ (E3) រួមទាំងវីដេអូ (E3/*R) ដែលបានបង្ហាញចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជាពិសេសភស្តុតាងដែលត្រូវបានយោងនៅក្នុងសាលក្រម និងសាលដីកា។

ឃ) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងភស្តុតាងមូលដ្ឋានដែលលែងត្រូវការការដាក់ចំណាត់ថ្នាក់សម្ងាត់តទៅទៀត។

ង) កំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹក ចម្លើយ សុន្ទរកថា និងការផ្សព្វផ្សាយ ឬឯកសារពាក់ព័ន្ធទៅនឹងជនជាប់ចោទ ឬពិរុទ្ធជនទាំងអស់។

ច) រាល់សេចក្តីសម្រេចរបស់តុលាការ ដីកា សាលក្រម និងញត្តិរបស់ភាគីពាក់ព័ន្ធទៅនឹងជនជាប់ចោទ ឬពិរុទ្ធជន ជនជាប់ចោទ ឬពិរុទ្ធជន។

ឆ) ឯកសារស៊ើបអង្កេត ជាពិសេសឯកសារដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២ ចំណុចដែលអង្គហេតុត្រូវបានកម្រិតដោយសេចក្តីសម្រេចបំបែកសំណុំរឿង ឬអង្គហេតុត្រូវបានដកចេញពីដីកាដំណោះស្រាយ ឬការជំនុំជម្រះ។

---

[5] ការឆ្លើយតបរបស់ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (F71/1/1/7) ទំព័រ ១។

[6] ការឆ្លើយតបរបស់ការិយាល័យរដ្ឋបាល (F71/1/1/2) កថាខណ្ឌ ៤។

[7] ឧបសម្ព័ន្ធ ក ឯកសារសម្ងាត់សំណុំរឿង ០០២ ដែលសាធារណៈក្នុងសំណុំរឿងដទៃទៀត ឯកសារលេខ F71/1/1/2.1 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២។

[8] ឧបសម្ព័ន្ធ ខ បញ្ជីឈ្មោះសំណុំរឿងពិសេសពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ឯកសារលេខ F71/1/1/2.2 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២។

ជ) រាល់ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជា និងឯកសារសម័យនោះដែលមានតម្លៃជាប្រវត្តិសាស្ត្រយ៉ាងខ្លាំង។

7. អង្គបុរេជំនុំជម្រះបានស្នើឡើងថា ឯកសារសម្ងាត់ ឬសាធារណៈដែលត្រូវបានកោសលុប ដែលមាននៅក្នុងអនុស្សរណៈពីដំបូងចំណងជើងថា "ឯកសារសម្ងាត់ និងសាធារណៈដែលត្រូវបានកោសលុបក្នុងសំណុំរឿង ០០២ ត្រូវបានស្នើឡើងឱ្យធ្វើចំណាត់ថ្នាក់ទៅជាសាធារណៈ"[9] ត្រូវដាក់ចំណាត់ថ្នាក់ជា "សាធារណៈ" ដោយហេតុថា ការដាក់ចំណាត់ថ្នាក់បច្ចុប្បន្នលែងចាំបាច់នៅដំណាក់នៃកិច្ចដំណើការនីតិវិធីនេះ[10]។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះបានផ្តល់អនុសាសន៍ថា ឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារ ឬមានការស្នើសុំឱ្យដាក់វិធានការការពារដែលមានអត្ថិភាព ត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់[11]។

8. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") បានឆ្លើយតបថា ព័ត៌មានលម្អិតទំនាក់ទំនងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគប្បីត្រូវរក្សាសម្ងាត់ ឬរក្សាទុកដូចមុន ដូចមានការបញ្ជាក់នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ[12]។ ពាក់ព័ន្ធទៅនឹងកថាខណ្ឌ ៤(ឆ) នៃសេចក្តីណែនាំដែលត្រូវបានស្នើឡើង[13] សហមេធាវីនាំមុខបានស្នើឡើងថា អង្គជំនុំជម្រះបានរួមបញ្ចូល

---

[9] ឯកសារសម្ងាត់ និងសាធារណៈដែលត្រូវបានកោសលុបក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឡើងសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅជាសាធារណៈ ឯកសារលេខ F67 ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២១។

[10] អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ ឯកសារលេខ F71/1/1/1 ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់អង្គបុរេជំនុំជម្រះ (F71/1/1/1)") កថាខណ្ឌ ៣-៤។

[11] ការឆ្លើយតបរបស់អង្គបុរេជំនុំជម្រះ (F71/1/1/1) កថាខណ្ឌ ៤។

[12] ការឆ្លើយតបរបស់សហមេធាវីនាំមុខ (F71/1/1/3) កថាខណ្ឌ ៤ យោងទៅលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៧.២ និង ៧.៣។ សហមេធាវីនាំមុខបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានបង្ហាញថា ប្រសិនបើព័ត៌មានទំនាក់ទំនងរបស់ពួកគេត្រូវបានផ្សព្វផ្សាយជាសាធារណៈ អាចនឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណងមិនត្រឹមត្រូវលើប្រព័ន្ធអ៊ីនធឺណែត និងទូរស័ព្ទ។

[13] អនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូល "ការពិនិត្យលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" ឯកសារលេខ F71/1/1 ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២ ("សំណើសុំសេចក្តីណែនាំ (F71/1/1)") កថាខណ្ឌ ៤(ឆ) ("ភាគីពាក់ព័ន្ធណាមួយរួមទាំងអង្គភាពគាំពារជនរងគ្រោះដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ [...] អាចស្នើសុំការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារដែលមានចំណាត់ថ្នាក់សម្ងាត់ ឬសម្ងាត់បំផុតក្រោយពីការបញ្ចប់នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ ក្នុងករណីនេះ ភាគីពាក់ព័ន្ធគប្បីបង្ហាញកាលៈទេសៈប្រែប្រួលដែលផ្តល់យុត្តិកម្មចំពោះការការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ")។

យ៉ាងជាក់លាក់នូវសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ជាភាគី និងថា ពួកគេតំណាងឱ្យ និងអនុវត្តក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ តាមរយៈការជួយគាំទ្រ និងសម្របសម្រួលពីអង្គភាពគាំពារជនរងគ្រោះ[14]។

9. ពួកគេបានទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះផងដែរលើប្រភេទព័ត៌មានដទៃទៀត ដែលដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវក្តីបារម្ភ ដូចជា ព័ត៌មានដែលបង្ហាញអត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ព័ត៌មានផ្ទាល់ខ្លួនផ្នែកវេជ្ជសាស្ត្រ បទពិសោធន៍ និងទិដ្ឋភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម រួមទាំងចម្លើយសារភាព និងប្រវត្តិរូបសង្ខេប និងឈ្មោះរបស់ចារីដែលត្រូវបានចោទប្រកាន់[15]។

10. សហមេធាវីនាំមុខបានស្នើឡើងថា អង្គជំនុំជម្រះ៖ (i) គប្បីគោរពតាមគោលការណ៍ស្តីពីឯកជន និងការឯកភាពដែលទទួលបានពាក់ព័ន្ធទៅនឹងការកោសលុបឯកសារដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនៅមុនពេលការធ្វើចំណាត់ថ្នាក់ឡើងវិញណាមួយ (ii) បញ្ជាក់ថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលនៅក្រៅមាត្រា ៤ នៃសេចក្តីណែនាំអនុវត្តនឹងពុំត្រូវធ្វើចំណាត់ថ្នាក់ជាសាធារណៈ ដោយគ្មានសំណើសុំដែលបង្ហាញអំពីការឯកភាពទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ និង (iii) បង្គាប់ឱ្យធ្វើចំណាត់ភ្លាមៗជាសម្ងាត់នូវរាល់ឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងទាំងអស់ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈពុំត្រឹមត្រូវ ឬគ្មានការកោសលុបសមស្របតាមសេចក្តីណែនាំអនុវត្តរហូតដល់មានលទ្ធផលនៃដំណើរការពេញលេញនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ[16]។

11. សហព្រះរាជអាជ្ញាបានគាំទ្រការកោសលុបព័ត៌មានសម្ងាត់ក្នុងឯកសារ ជាជាងការធ្វើចំណាត់ថ្នាក់លើឯកសារទាំងមូលជាសម្ងាត់ និងបានអះអាងថា នេះគឺដើម្បីអត្ថប្រយោជន៍នៃកេរដំណែលរបស់ អ.វ.ត.ក. ដែលបានលះបង់ធនធាន និងហិរញ្ញវត្ថុនៅក្នុងដំណើរការពិនិត្យ និងកោសលុប[17]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានស្នើឡើងថា អង្គជំនុំជម្រះបង្កើតគោលនយោបាយចូលមើលឯកសារដោយមានសេចក្តីណែនាំដែលគ្រប់គ្រងលើការចូលមើលឯកសារទាំងអស់ដែលសម្ងាត់ ឬសម្ងាត់បំផុត[18]។ សហព្រះរាជអាជ្ញាជម្រុញឱ្យអង្គជំនុំជម្រះផ្តល់ការចូលមើលជាសាធារណៈឱ្យបានច្រើនទៅលើឯកសារដូច

[14] ចម្លើយតបរបស់សហមេធាវីនាំមុខ (F71/1/1/3) កថាខណ្ឌ ៣។

[15] ចម្លើយតបរបស់សហមេធាវីនាំមុខ (F71/1/1/3) កថាខណ្ឌ ៥។

[16] ចម្លើយតបរបស់សហមេធាវីនាំមុខ (F71/1/1/3) កថាខណ្ឌ ៦-១០, ១២។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤។

[18] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥។

ជា ចម្លើយសារភាព និងប្រវត្តិរូបសង្ខេបនាពេលអនាគត និងជាពិសេសស្នើឡើងថា អាជ្ញាធរស្នងតំណែងបន្ត អ.វ.ត.ក. កែប្រែទៅជាសាធារណៈជាស្វ័យប្រវត្តិនូវឯកសារសម្ងាត់ទាំងអស់ក្នុងរយៈពេល ២០ ឆ្នាំក្រោយការបិទ អ.វ.ត.ក. និងធ្វើការពិនិត្យរាល់ឯកសារ"សម្ងាត់បំផុត"ក្នុងរយៈពេល ២០ ឬ៥០ ឆ្នាំក្រោយការបិទ អ.វ.ត.ក. ថាតើមានមូលហេតុជឿជាក់ដែលមានអត្ថិភាពក្នុងការផ្តល់យុត្តិកម្មបន្តរក្សាការសម្ងាត់ ដែរ ឬយ៉ាងណា[19]។

12. សហព្រះរាជអាជ្ញាបានស្នើថា អង្គជំនុំជម្រះលុបចោលកថាខណ្ឌ ៤(ក)(vi) នៃសេចក្តីណែនាំដែលបានស្នើឡើងនោះ[20] ក្នុងកម្រិតមួយដែលការដាក់ចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿងដទៃទៀតលែងមានសារៈសំខាន់ដូចកាលដែលកិច្ចដំណើរការនីតិវិធីរួមទាំងកិច្ចស៊ើបសួរសម្ងាត់តាមផ្លូវតុលាការកំពុងបន្តនោះ [21]។

13. ពាក់ព័ន្ធនឹងកថាខណ្ឌ ៤(ង)[22] សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះគប្បីប្រុងប្រយ័ត្នដោយមិនត្រូវរឹតត្បិតមិនហេតុផលដល់សាធារណៈដែលមានបំណងប្រើប្រាស់ត្រឹមត្រូវនូវទីកន្លែង អ.វ.ត.ក. សម្រាប់គោលបំណងសិក្សា និងស្រាវជ្រាវ ដូចបានទទួលស្គាល់ដោយច្បាប់ស្តីពីការរក្សាសិទ្ធិអ្នកនិពន្ធរបស់រដ្ឋនានា ខណៈពេលការពារសិទ្ធិរបស់អ្នកនិពន្ធ[23]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើឡើងថា ប្រហាក់ប្រហែលទៅនឹងវិធីសាស្ត្រដែលបានអនុម័តដោយយន្តការកេរដំណែលអន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("IRMCT") នៅលើគេហទំព័រថា តុលាការអាចតម្រូវឱ្យអ្នកប្រើប្រាស់ដែលចង់ចូលមើលឯកសារនានាត្រូវទទួលយកលក្ខខណ្ឌមួយចំនួនក្នុងគោលនយោបាយស្តីពីការចូលមើលឯកសារដូចខាងក្រោម[24]៖

---

[19] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៩។

[20] សំណើសុំសេចក្តីណែនាំ (F71/1/1) កថាខណ្ឌ ៤(ក)(iv) ("ឯកសារដែលមានក្នុងសំណុំរឿងដទៃទៀត និងត្រូវបានដាក់ចំណាត់ថ្នាក់សម្ងាត់ ត្រូវរក្សាទុកសម្ងាត់")។

[21] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៤។

[22] សំណើសុំសេចក្តីណែនាំ(F71/1/1) កថាខណ្ឌ ៤(ង) ("ឯកសារសាធារណៈ មិនត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈ ក្នុងករណីដែល៖ (ក) ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធជាធរមាន ឬ (ខ) ស្ថិតក្រោមការយល់ព្រមជាមួយតតិយជនដែលបានហាមឃាត់ការផ្សព្វផ្សាយ [...] លើកលែងមានការអនុញ្ញាតពីតតិយជននោះ")។

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៦-៧៨។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៨។

i. អ្នកប្រើប្រាស់ត្រូវទទួលស្គាល់ថា ការអនុញ្ញាតរបស់ អ.វ.ត.ក. ឱ្យចូលមើលឯកសារពុំគប្បីបកស្រាយថា ជាការលះបង់សិទ្ធិអ្នកនិពន្ធនោះឡើយ។

ii. ស្របជាមួយនឹងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធដែលអនុវត្តក្នុងយុត្តាធិការរបស់អ្នកប្រើប្រាស់ អ្នកប្រើប្រាស់អាចប្រើប្រាស់សម្ភារៈដោយត្រឹមត្រូវសម្រាប់ការស្រាវជ្រាវដែលពុំមែនជាពាណិជ្ជកម្ម សម្រាប់ការសិក្សា ឬការអប់រំ។

iii. ប្រសិនបើអ្នកប្រើប្រាស់ចង់ប្រើប្រាស់ក្នុងគោលបំណងផ្សេងរួមមានការផ្សព្វផ្សាយបន្ថែម ត្រូវស្នើសុំការអនុញ្ញាតសិទ្ធិថតចម្លង។

14. យោងតាមមាត្រា ៥.១ (ក) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ[25] សហព្រះរាជអាជ្ញាបានអះអាងថា វិធាន ៥៤ ស្តីពីការដាក់ចំណាត់ថ្នាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរជាសម្ងាត់ លែងមានភាពចាំបាច់ ប៉ុន្តែត្រូវស្ថិតក្រោមការកោសលុបក្នុងកម្រិតមួយ ពីព្រោះវិសាលភាពនៃសំណុំរឿង ០០២ ដូចបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈនៅក្នុងដីកាដំណោះស្រាយ ក្នុងសាលក្រមសំណុំរឿង ០០២/០១ និង ០០២/02 និង សាលដីកាសំណុំរឿង ០០២/០២[26]។

15. ស្របតាមមាត្រា ៥.១ (ច) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ[27] ឯកសារទាំងនេះគប្បីដាក់ចំណាត់ថ្នាក់សាធារណៈផ្អែកតាមវិធានការការពារជាធរមាន និងការកោសលុបព័ត៌មានដែលរសើប[28]។ ពាក់ព័ន្ធមាត្រា ៥.១ (ខ) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ[29] សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលចាំបាច់សម្រាប់គោល

[25] សេចក្តីណែនាំអនុវត្ត 00៤/២00៩ ការដាក់ចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធសំណុំរឿង ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ") មាត្រា ៥.១ (ក) ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា")។

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤២។

[27] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ មាត្រា ៥.១ (ច) ("សេចក្តីសម្រេច ដីកាបង្គាប់ និងកិច្ចដទៃទៀតរបស់សហចៅក្រមស៊ើបអង្កេត")។

[28] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៤។

[29] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ មាត្រា ៥.១ (ខ) ("សំណុំឯកសារដែលទទួលបាន និងភស្តុតាងដែលផ្តល់ឱ្យនៅដំណាក់កាលស៊ើបអង្កេតរបស់តុលាការ")។

បំណងនៃភស្តុតាង និងជាប្រវត្តិសាស្ត្រ គប្បីដាក់ចំណាត់ថ្នាក់ជាសាធារណៈ លើកលែងករណីពិសេសមួយចំនួន[30]។ ពាក់ព័ន្ធនឹងបញ្ជីឈ្មោះអ្នកជាប់ឃុំ សហព្រះរាជអាជ្ញាអះអាងថា ដោយសារឯកសារទាំងនេះពុំមែនជាលទ្ធផលនៃការធ្វើទារុណកម្ម ឯកសារនេះគប្បីធ្វើចំណាត់ថ្នាក់ជាសាធារណៈ ហើយឈ្មោះរបស់ជនរងគ្រោះគប្បីកោសលុបតែក្នុងករណីចាំបាច់ ដូចជានៅពេលតម្រូវដោយវិធានការការពារ ឬដើម្បីការពារជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងផ្អែកលើភេទ[31]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញជាពិសេសថា កថាខណ្ឌ ៤(ក)(iv) នៃសេចក្តីណែនាំដែលបានស្នើឡើង[32] ដែលដោះស្រាយជាមួយ "ឈ្មោះ [...] របស់ជនរងគ្រោះដែលពុំមែនជាដើមបណ្តឹងរដ្ឋប្បវេណី" មានលក្ខណៈទូលំទូលាយពុំសមមាត្រ[33]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ដោយសារពាក្យថា "ជនរងគ្រោះ" ពុំត្រូវបានកំណត់និយមន័យ សេចក្តីណែនាំនេះតម្រូវ*ក្នុងចំណោមនោះ* ការកោសលុបឈ្មោះរបស់ជនរងគ្រោះចេញពីឯកសារនីមួយៗក្នុងសំណុំរឿងរួមទាំងជនរងគ្រោះនៃការជម្លៀសដោយបង្ខំ និងបុគ្គលដែលមានក្នុងបញ្ជីឈ្មោះ ស-២១[34]។ ដូចគ្នាដែរ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការកោសលុបព័ត៌មានរសើបចេញពីឯកសារ"ចម្លើយសារភាព" ដែលតាមការសន្មតបានបង្កើតឡើងតាមរយៈការធ្វើទារុណកម្ម ឬការគំរាមកំហែង បានលើកកម្ពស់កេរដំណែលជាប្រវត្តិសាស្ត្រ និងជាការអប់រំតាមរយៈការបន្សល់ទុកព័ត៌មានដ៏មានតម្លៃ ដូចជាចំណាររបស់ ឌុច និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដែលឯកសារនេះអាចចូលមើលបានជាសាធារណៈជាជាងការដាក់ចំណាត់ថ្នាក់ចម្លើយសារភាពជាសម្ងាត់ទាំងស្រុង[35]។

16. ប្រហាក់ប្រហែលគ្នានេះ សហព្រះរាជអាជ្ញាបានស្នើឡើងថា ព័ត៌មានបង្ហាញអត្តសញ្ញាណក្នុងប្រវត្តិរូបដែលប្រមូលផ្តុំនៅមន្ទីរ ស-២១ និងមន្ទីរសន្តិសុខដទៃទៀត គប្បីដាក់ចំណាត់ថ្នាក់សម្ងាត់ និងថាប្រវត្តិរូបដែលដាក់ចំណាត់ថ្នាក់ជាសាធារណៈទាំងមូលត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញ (ដោយការកោសលុប) [36]។ សហព្រះរាជអាជ្ញាបានផ្តល់យោបល់ផងដែរក្នុងការរក្សាការសម្ងាត់ ឬការធ្វើចំណាត់ថ្នាក់ឡើងវិញលើ

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៦។

[31] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៨-៤៩។

[32] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៩ សំណើសុំសេចក្តីណែនាំ (F71/1/1) កថាខណ្ឌ ៤(ក)(iv) ("ឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់ជនរងគ្រោះដែលពុំមែនជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងនៅក្នុងសំណុំរឿងដែលព័ត៌មាននេះបានរួមបញ្ចូលពាក្យបណ្តឹងរបស់ជនរងគ្រោះ"។

[33] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៩។

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៤៩។

[35] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥១។

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៣។

ព័ត៌មានដែលបង្ហាញអត្តសញ្ញាណ និង/ឬរសើបដែលមានក្នុងកូនសៀវភៅកំណត់ហេតុទាំងនេះទៅជាសម្ងាត់ ដោយសារឯកសារទាំងនេះអាចមានព័ត៌មានលម្អិតនៃចម្លើយសារភាពរបស់អ្នកជាប់ឃុំដែលតាមការសន្មតទទួលបានតាមរយៈការធ្វើទារុណកម្ម[37]។

17. សហព្រះរាជអាជ្ញាបានបញ្ជាក់បន្ថែមទៀតថា ព័ត៌មានខាងក្រោមគប្បីរក្សាសម្ងាត់បំផុត[38]៖ (i) សំណើសម្រាប់វិធានការការពារ និងឯកសារពាក់ព័ន្ធ (ii) ឯកសារ និងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ (iii) ព័ត៌មានពាក់ព័ន្ធទៅនឹងជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ និង (iv) ឯកសារដទៃទៀតដែលហេតុផលសម្រាប់ការធ្វើចំណាត់ថ្នាក់សម្ងាត់បំផុតនៅមានអត្ថិភាព។

18. សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគប្បីពិចារណាការកោសលុបព័ត៌មានរសើប ឧទាហរណ៍ ពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទ និងផ្អែកលើភេទ ព័ត៌មានផ្នែកវេជ្ជសាស្ត្ររបស់អ្នកដាក់ពាក្យបណ្តឹង របស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ឬព័ត៌មានដែលបង្ហាញអត្តសញ្ញាណចារីដែលត្រូវបានចោទប្រកាន់ដែលត្រូវបានបង្ហាញឈ្មោះដោយដើមបណ្តឹងរដ្ឋប្បវេណី ត្រង់ចំណុចដែលព័ត៌មាននោះពុំត្រូវបានដាក់ចំណាត់ថ្នាក់សាធារណៈក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះ[39]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានគូសបង្ហាញថា សំណើសុំកែតម្រូវលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងលិខិតបញ្ជាក់ស្តីពីការជំនួសឯកសារ មានតម្លៃតិចតួច[40]។

19. សហព្រះរាជអាជ្ញាបានផ្តល់យោបល់ឱ្យមានការប្រុងប្រយ័ត្ន នៅពេលឯកសារពាក់ព័ន្ធទៅនឹងដំណើរការស៊ើបអង្កេតមានព័ត៌មានលម្អិតសម្ងាត់ទាក់ទងទៅនឹងសាក្សីនាំមុខ ឬសក្ខីបុគ្គល រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី[41]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា របាយការណ៍របស់អង្គភាព WESU និងការវាយតម្លៃអំពីហានីភ័យ លិខិតធានា សំបុត្រកំណើត ឬមរណភាព អត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ពាក្យបណ្តឹង សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងលិខិតទាក់ទងទៅនឹងសេវាបញ្ជូនឯកសារ គប្បីរក្សាសម្ងាត់[42]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារដែលសមស្របសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅជាសាធារណៈដែលត្រូវធ្វើការកោសលុបព័ត៌មានរសើប

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៥។

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៦។

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៧។

[40] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៧។

[41] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៥៨។

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៦០។

រួមបញ្ចូលលិខិតឆ្លើយឆ្លងរវាងភាគី និងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះព្រមទាំងការឆ្លើយឆ្លងរវាង អ.វ.ត.ក. អង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងការិយាល័យរដ្ឋបាល[43]។

20. ទាក់ទងនឹង"ដីកាចាត់ឱ្យស៊ើបសួរជំនួស និងរបាយការណ៍" សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា ឯកសារទាំងនេះគប្បីធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈដោយមានការកោសលុបដោយប្រុងប្រយ័ត្ននូវព័ត៌មានរសើប និងបង្ហាញអត្តសញ្ញាណ ដោយសារឯកសារស៊ើបអង្កេតទាំងនេះជាញឹកញាប់មានព័ត៌មានដែលចាំបាច់ត្រូវការពារ[44]។ សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ផងដែរថា ដីកាកោះគប្បីធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈដែលចេញសម្រាប់ជនជាប់ចោទ និង/មេធាវីក្នុងសំណុំរឿង ០០២ ដើម្បីឱ្យពួកគេចូលខ្លួនជាបឋម និងបន្តបន្ទាប់ចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ រួមទាំងសវនាការលើការឃុំខ្លួនបណ្តោះអាសន្ន ព្រមទាំងសវនាការចំពោះមុខអង្គជំនុំជម្រះ និងដីកាចាប់ខ្លួន[45]។

21. ពាក់ព័ន្ធទៅនឹងចម្លើយ និងភស្តុតាងសក្ខីកម្ម សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា លើកលែងករណីពិសេសមួយចំនួន និងក្រោយពីការពិនិត្យដោយប្រុងប្រយ័ត្នក្នុងការកោសលុបព័ត៌មានឯកជន និងរសើប ឯកសារទាំងនេះគប្បីធ្វើចំណាត់ថ្នាក់ជាសាធារណៈជាទូទៅ ពីព្រោះដើម្បីឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ ព្រឹត្តិការណ៍ និងបទចោទក្នុងរឿងក្តីនេះ[46]។

22. ចំពោះឯកសាររបស់បណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី រួមទាំងប្រតិចារឹក និងកំណត់ហេតុថតសម្លេង និងវីដេអូ សហព្រះរាជអាជ្ញាជឿជាក់ថា ដើម្បីអត្ថប្រយោជន៍នៃការអប់រំ កេរដំណែល និងការពង្រឹងសមត្ថភាព កំណត់ហេតុស្តាប់ចម្លើយ កំណត់ហេតុ DC-Cam និងប្រតិចារឹកស្តាប់ចម្លើយប្រតិចារឹកការជំនុំជម្រះសំណុំរឿង ០០១ ឯកសារផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងគប្បីធ្វើចំណាត់ថ្នាក់សាធារណៈដោយស្ថិតក្រោមការកោសលុបព័ត៌មានលម្អិតទំនាក់ទំនង និងព័ត៌មានរសើបដទៃទៀតព្រមទាំងការពិគ្រោះពិភាក្សាសមស្របជាមួយដើមបណ្តឹងរដ្ឋប្បវេណី[47]។ សហព្រះរាជអាជ្ញាបានពិចារណាឃើញថា ឯកសាររដ្ឋបាល ដូចជាចម្លើយលះបង់សិទ្ធិមានវត្តមានរបស់មេធាវីតំណាង

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៦០។

[44] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៦២។

[45] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៦៣។

[46] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៦៨។

[47] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧១។

ដើមបណ្តឹងរដ្ឋប្បវេណី និងការធ្វើសម្បថរបស់បុគ្គលផ្សេងៗ ពុំគ្រប់គ្រាន់សម្រាប់ការកែប្រែចំណាត់ថ្នាក់ឯកសារឡើយ[48]។

23. ជាការឆ្លើយតបទៅនឹងកថាខណ្ឌ ៤(ក)(v) នៃសេចក្តីណែនាំដែលត្រូវបានស្នើឡើង[49] សហព្រះរាជអាជ្ញាបានអះអាងថា សវនាការ*ជាសម្ងាត់* ពុំបានបណ្តាលជាស្វ័យប្រវត្តិឱ្យមានការដកប្រតិចារឹក និងកំណត់ត្រាចេញពីសាធារណៈ និងថា ឯកសារទាំងនេះគប្បីធ្វើចំណាត់ថ្នាក់សាធារណៈដោយត្រូវកោសលុបព័ត៌មានរសើប និងដាក់ឱ្យស្ថិតក្រោមវិធានការការពារជាអត្តិភាព[50]។

24. ចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា របាយការណ៍ស៊ើបអង្កេតតាមតំបន់របស់ DC-Cam អាចត្រូវដាក់ចំណាត់ថ្នាក់ជាសាធារណៈដោយគ្មានហានីភ័យ[51]។ សហព្រះរាជអាជ្ញាបានផ្តល់អនុសាសន៍ថា របាយការណ៍ស្តីពីការបង្ហាញទីតាំងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ចំណាត់ថ្នាក់ជាសាធារណៈ ប៉ុន្តែបន្ទាប់ពីការកំណត់ថាតើ មានការកោសលុបត្រូវបានធ្វើឡើងដើម្បីការពារព័ត៌មានរសើបនោះដែរ ឬយ៉ាងណា[52]។

## III. ការពិភាក្សា

### ក. <u>គោលការណ៍ទូទៅ</u>

25. ដោយស្របតាមគោលបំណងរបស់តុលាការសម្រាប់ការសិក្សាអប់រំ និងកេរដំណែល អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការធ្វើចំណាត់ថ្នាក់ឯកសារត្រូវតែកំណត់តាមរយៈការថ្លឹងថ្លែងអំពីភាពចាំបាច់នៃការសម្ងាត់ ជាមួយនឹងតម្រូវការឱ្យមានតម្លាភាពដែលកើតចេញពីគោលការណ៍មូលដ្ឋានដែលគ្រប់គ្រងនីតិវិធីចំពោះមុខ អ.វ.ត.ក.[53]។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា "ការផ្សព្វផ្សាយទូលំទូលាយនូវសម្ភារៈពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីចំពោះមុខតុលាការនេះ [...] ជាការសមស្របជាមួយ

---

[48] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧១។

[49] សំណើសុំសេចក្តីណែនាំ (F71/1/1) កថាខណ្ឌ ៤(ក)(v) ("កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក និងការថតវីដេអូ និងសម្លេងនៃសវនាការដែលបានធ្វើឡើងសម្ងាត់ លើកលែងហេតុផលសម្រាប់ការរក្សាចំណាត់ថ្នាក់សម្ងាត់លែងមានសុពលភាព")។

[50] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧២។

[51] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៣។

[52] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (F71/1/1/4) កថាខណ្ឌ ៧៣។

[53] *សូមមើល* វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ មាត្រា ១.២។

នឹងអាណត្តិរបស់ អ.វ.ត.ក. ដែលរួមបញ្ចូលការរួមចំណែកដល់ការសម្រុះសម្រួលជាតិ និងផ្តល់ការគាំទ្រជាឯកសារដល់ការស្វះស្វែងរកការពិតជាប្រវត្តិសាស្ត្រ"[54]។ ការផ្សព្វផ្សាយដ៏ទូលំទូលាយនៃឯកសារសំខាន់ជាច្រើនក្នុងសំណុំរឿងអាចជួយជម្រុញ"ការពិភាក្សាជាសាធារណៈដោយពិតប្រាកដអំពីអតីតកាលដោយផ្អែកលើមូលដ្ឋានរឹងមាំ ដូច្នេះបានកាត់បន្ថយការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការពិតក្នុងផ្នែកខ្លះ"[55]។

26. គួរកត់សម្គាល់ សម្ភារៈភាគច្រើនដែលមានតម្លៃក្នុងសំណុំរឿង ត្រូវបានប្រមែប្រមូលក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ។ ដោយសារកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បានបញ្ចប់ដោយប្រសិទ្ធភាព ការដកចំណាត់ថ្នាក់ឯកសារដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរនោះលែងបង្កហានីភ័យដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ឬសុចរិតភាពនៃកិច្ចស៊ើបសួរទៀតឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ជាគោលការណ៍ រាល់ឯកសារទាំងអស់គប្បីធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ដោយអនុញ្ញាតឱ្យមានការចូលពិនិត្យឯកសារនោះដោយពេញលេញដល់សាធារណៈ និងតម្លាភាពជាអតិបរមា។ បើទោះបីជាកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក. ត្រូវបានបញ្ចប់ក៏ដោយ ក៏នៅមានហេតុផលដែលមានសុពលភាពមួយចំនួនសម្រាប់រក្សាការសម្ងាត់ ក្នុងន័យនេះត្រូវមានការការពារក្នុងកម្រិតមួយដូចបានរៀបរាប់ក្នុងសេចក្តីណែនាំខាងក្រោម។

27. អង្គជំនុំជម្រះតុលាការកំពូលនឹងកំណត់ប្រភេទឯកសារ ជាពិសេសក្នុងករណីដែលសារណាបានបង្ហាញអំពីភាពមិនស្របគ្នាជាមួយនឹងសំណើសុំសេចក្តីណែនាំពីដំបូង។ ឯកសារប្រភេទនោះ អង្គជំនុំជម្រះនឹងបង្គាប់ឱ្យធ្វើការកោសលុប ប្រសិនបើចាំបាច់។

28. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ថា ជាភាគីក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ហើយការសង្កេតរបស់ពួកគេត្រូវបានពិចារណាពេញលេញ។ សហព្រះរាជអាជ្ញាជាទូទៅបានគាំទ្រការកោសលុបព័ត៌មានសម្ងាត់ក្នុងឯកសារជាជាងការធ្វើចំណាត់ថ្នាក់ទាំងមូលជាសម្ងាត់។ ទោះជាយ៉ាងណាក្តី ប្រសិនបើការកោសលុបពុំអាចការពារគ្រប់គ្រាន់ដល់អត្ថប្រយោជន៍

---

[54] សេចក្តីសម្រេចនៃសំណុំរឿង ០០១ ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ F30/2 ("សេចក្តីសម្រេចសំណុំរឿង ០០១ ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ (F30/2)") កថាខណ្ឌ ៥។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ F28 ("សាលដីកាសំណុំរឿង ០០១ (F28)") កថាខណ្ឌ ៧០៨។

[55] សេចក្តីសម្រេចនៃសំណុំរឿង ០០១ ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ (F30/2) កថាខណ្ឌ ៥។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៧០៨។

ត្រឹមត្រូវរបស់បុគ្គល ដូចជា សន្តិសុខ និងភាពឯកជន ដែលត្រូវតែគោរពនោះទេ ឯកសារនេះត្រូវដាក់ចំណាត់ថ្នាក់សម្ងាត់។ អង្គជំនុំជម្រះតុលាការកំពូលនឹងដកចំណាត់ថ្នាក់ឯកសារដែលបានរួមបញ្ចូលក្នុងអនុស្សរណៈពីដំបូងរបស់អង្គបុរេជំនុំជម្រះ[56] ជាសាធារណៈដោយមានការកោសលុបឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គល ពីព្រោះការដាក់ចំណាត់ថ្នាក់បច្ចុប្បន្ន លែងមានលក្ខណៈសមស្របក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ[57]។

29. ដោយពិចារណាលើគោលការណ៍ទូទៅ និងមាត្រា ៤, ៥ និង ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ ព្រមទាំង សារណានានាដែលទទួលបានពីភាគីពាក់ព័ន្ធ អង្គជំនុំជម្រះ និងអង្គភាពនៃ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលអនុម័តនូវសេចក្តីណែនាំចុងក្រោយដូចខាងក្រោមសម្រាប់ការប្រើប្រាស់ក្នុងអំឡុងពេលនៃដំណើរការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងការគ្រប់គ្រងដែលនៅមានអត្ថិភាពលើសំណុំរឿង ០០២៖

ក. ឯកសារ ឬផ្នែកណាមួយនោះដែលពុំស្ថិតក្នុងកថាខណ្ឌ (ខ) ឬ (គ) ខាងក្រោមត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាសាធារណៈ។

ខ. ឯកសារខាងក្រោម ឬផ្នែកនោះត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់៖

i. ព័ត៌មានលម្អិតទំនាក់ទំនងរបស់ជនរងគ្រោះដែលពុំមែនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២[58] រួមទាំងក្នុងសំណុំរឿងដែលព័ត៌មាននោះអាចកំណត់បានក្នុងពាក្យបណ្តឹងរបស់ជនរងគ្រោះ។

[56] ឯកសារសម្ងាត់ និងសាធារណៈដែលកោសលុបក្នុងសំណុំរឿង ០០២ សម្រាប់ការធ្វើចំណាត់ឡើងវិញជាសាធារណៈ: ឯកសារលេខ F67 ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២១។

[57] អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ ឯកសារលេខ F71/1/1/1 ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២ ("ការឆ្លើយតបរបស់អង្គបុរេជំនុំជម្រះ (F71/1/1/1)") កថាខណ្ឌ ៣-៤។

[58] សម្រាប់គោលបំណងនៃសេចក្តីណែនាំនេះ "ជនរងគ្រោះ"សំដៅទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារការប្រព្រឹត្តនូវឧក្រិដ្ឋកម្មណាមួយក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។ ការកំណត់និយមន័យនេះត្រូវបានទាញចេញពីសន្ទានុក្រមនៃវិធានផ្ទៃក្នុង។

ii. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក និងការថតសម្លេង/វីដេអូនៃសវនាការសម្ងាត់ លើកលែងហេតុផលសម្រាប់រក្សាការសម្ងាត់លែងមានសុពលភាព[59]។

គ. ឯកសារខាងក្រោម ឬផ្នែកនោះត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់បំផុត៖

i. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ។

ii. ឯកសារ និងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ។

iii. ព័ត៌មានពាក់ព័ន្ធទៅនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ។

iv. ឯកសារដទៃទៀតដែលមូលហេតុសម្រាប់ការធ្វើចំណាត់ថ្នាក់សម្ងាត់បំផុតនៅមានអត្ថិភាព។

---

[59] អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារទាំងនេះគប្បីត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈដោយមានការកោសលុបក្នុងកម្រិតទូលំទូលាយតាមដែលអាចធ្វើទៅបាន។ *សូមមើល* សំណុំរឿង ០០៤/១ (PTC54) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំការធ្វើចំណាត់ថ្នាក់ឡើងវិញលើសារណាតបរបស់លោកស្រីទៅនឹងដីកាសន្និដ្ឋានស្ថាពរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារលេខ D304/6/4 កថាខណ្ឌ ២៨ (ពាក់ព័ន្ធទៅនឹងការធ្វើចំណាត់ថ្នាក់ឡើងវិញនូវសវនាការសម្ងាត់ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ការដែលសវនាការត្រូវធ្វើឡើងសម្ងាត់ ជាស្វ័យប្រវត្តិពុំបានធ្វើឱ្យប្រតិចារឹកលែងទៅជាសាធារណៈនោះឡើយ។ ការគ្រប់គ្រងតុលាការ និងការដាក់ចំណាត់ថ្នាក់ឯកសារត្រូវបានគ្រប់គ្រងដោយលិខិតុបករណ៍ច្បាប់ផ្សេងៗ និងមានគោលបំណងផ្សេង។ ការដាក់ចំណាត់ថ្នាក់ឯកសារត្រូវបានគ្រប់គ្រងដោយសេចក្តីណែនាំអនុវត្តពាក់ព័ន្ធ ខណៈពេលសវនាការត្រូវបានគ្រប់គ្រងដោយវិធានផ្ទៃក្នុង”), កថាខណ្ឌ ២៩ (អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា៖ ‘**កំណត់ហេតុលាយលក្ខណ៍អក្សរ ប្រិតិចារឹក និងការថតជាវីដេអូ/សម្លេងសវនាការសម្ងាត់**’ ‘ជាគោលការណ៍មានចំណាត់ថ្នាក់សម្ងាត់’ **លើកលែងតែការដាក់ចំណាត់ថ្នាក់ផ្សេងត្រូវបានបង្គាប់ដោយសេចក្តីសម្រេចតុលាការ។** អាស្រ័យហេតុនេះ ពុំមានសេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ប្រតិចារឹកសវនាការសម្ងាត់ ស្ថាពរឡើយ ដោយសារការធ្វើចំណាត់ថ្នាក់នោះអាចកែប្រែដោយសេចក្តីសម្រេចរបស់តុលាការ។ សំអាងហេតុនេះអនុវត្តទៅលើការធ្វើចំណាត់ថ្នាក់នៃការថតវីដេអូ/សម្លេងនៃសវនាការទាំងនោះ”)។

ឃ. ប្រសិនបើឯកសារមានផ្នែកខ្លះដែលគប្បីដាក់ចំណាត់ថ្នាក់សម្ងាត់ និងផ្នែកខ្លះគប្បីដាក់ចំណាត់ថ្នាក់សម្ងាត់ ឬសម្ងាត់បំផុត ត្រូវអនុវត្តតាមមាត្រា ៣.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ។

ង. ឯកសារសាធារណៈពុំត្រូវដាក់ឱ្យស្ថិតក្រោមការផ្សព្វផ្សាយជាសាធារណៈដែលឯកសារនោះ៖ (ក) ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធជាធរមាន[60] ឬ (ខ) "ស្ថិតក្រោមកិច្ចព្រមព្រៀងជាមួយតតិយជន ដែលហាមឃាត់ការផ្សព្វផ្សាយ [...] លើកលែងមានការអនុញ្ញាតពីតតិយជននោះ"[61]។

ច. អង្គជំនុំជម្រះតុលាការកំពូលរក្សាយុត្តាធិការដាក់ទណ្ឌកម្ម ស្របតាមវិធានផ្ទៃក្នុងលើការផ្សព្វផ្សាយជាសាធារណៈនៃព័ត៌មានដែលត្រូវបានដាក់ចំណាត់ថ្នាក់សម្ងាត់នោះ។

ឆ. ភាគីពាក់ព័ន្ធ រួមទាំងសហព្រះរាជអាជ្ញា អង្គភាពគាំពារការការពារក្តីដែលតំណាងឱ្យជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ សហមេធាវីនាំមុខ និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ តាមរយៈការជួយ និងគាំទ្រពីពីអង្គភាពគាំពារជនរងគ្រោះ សាក្សី និងអ្នក

[60] អង្គជំនុំជម្រះនឹងត្រូវអនុម័តគោលការណ៍ចូលមើលឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាថា៖ អ.វ.ត.ក. អាចតម្រូវឱ្យអ្នកប្រើប្រាស់ស្នើសុំការចូលមើលកំណត់ត្រា ត្រូវទទួលយកលក្ខខណ្ឌមួយចំនួនក្នុងគោលនយោបាយស្តីពីការចូលមើលឯកសារដូចខាងក្រោម៖

i. អ្នកប្រើប្រាស់ត្រូវទទួលស្គាល់ថា ការអនុញ្ញាតឱ្យចូលមើលឯកសារ អ.វ.ត.ក. ពុំគប្បីត្រូវបានចាត់ទុកថា ជាការលះបង់សិទ្ធិអ្នកនិពន្ធ។

ii. អ្នកប្រើប្រាស់អាចប្រើប្រាស់សមស្របនូវឯកសារសម្រាប់គោលបំណងសិក្សា ឬការអប់រំដែលពុំមែនជាការធ្វើពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធជាធរមានក្នុងយុត្តាធិការរបស់អ្នកប្រើប្រាស់។

iii. ប្រសិនបើអ្នកប្រើប្រាស់មានបំណងប្រើប្រាស់ដទៃទៀតលើឯកសាររួមទាំងការផ្សព្វផ្សាយ ត្រូវទទួលការអនុញ្ញាតពីអ្នកគ្រប់គ្រងលើសិទ្ធិអ្នកនិពន្ធ។ អង្គជំនុំជម្រះគប្បីប្រុងប្រយ័ត្នក្នុងការកម្រិតដោយពុំសមស្របលើការចូលមើលឯកសារដល់សាធារណៈជន។ គេហទំព័រតុលាការ IRMCT បានស្នើឡើងថា អង្គជំនុំជម្រះត្រូវឱ្យអ្នកប្រើប្រាស់ស្នើសុំការអនុញ្ញាតចូលមើលឯកសារ ត្រូវទទួលយកលក្ខខណ្ឌមួយចំនួនក្នុងគោលការណ៍ចូលមើលឯកសារ ដើម្បីទទួលបានការអនុញ្ញាតដោយគ្មានការរំលោភបំពានលើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។

[61] មាត្រា ១២.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ។

ជំនាញ ឬផ្នែកកិច្ចការសាធារណៈ អាចស្នើសុំការដាក់ចំណាត់ថ្នាក់ឡើងវិញនូវឯកសារណាមួយដែលសម្ងាត់ ឬសម្ងាត់បំផុតបន្ទាប់ពីការបញ្ចប់ដំណើរការនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ ក្នុងករណីនេះ ភាគីពាក់ព័ន្ធគប្បីបង្ហាញកាលៈទេសៈប្រែប្រួលដែលផ្ដល់យុត្តិកម្មដល់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។

30. សាធារណៈនឹងត្រូវជូនដំណឹងសមស្របអំពីការបញ្ចប់ដំណើរការនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនោះ។

## ខ. ដំណើរការនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ

### *១. ការកំណត់ប្រភេទឯកសារ*

31. ដើម្បីសម្រួលដល់ការចងក្រងឧបសម្ព័ន្ធឱ្យមានប្រសិទ្ធភាពដែលមានភ្ជាប់ជាមួយនឹងសេចក្ដីសម្រេច និងដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនេះ ឯកសារសម្ងាត់ក្នុងសំណុំរឿង ០០២ នឹងត្រូវកំណត់ប្រភេទទៅតាមភាគីដែលបានដាក់នោះ ឧ. ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា មេធាវីការពារក្ដី៖ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ខៀវ សំផន នួន ជា អៀង សារី អៀង ធីរិទ្ធ និងអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូល អង្គភាពគ្រប់គ្រងតុលាការ អង្គភាពគាំពារការការពារក្ដី និងដទៃទៀតរួមទាំងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

32. ស្របជាមួយនឹងដំណើរការនីតិវិធីនៃការកំណត់ប្រភេទឯកសារ ឯកសាររបស់ភាគីនីមួយៗនឹងត្រូវចងក្រងតាមប្រភេទឯកសារមានដូចជា៖

ក) សារណា ញត្តិ សំណើ (អង្គសេចក្ដី)

ខ) ភស្តុតាង

គ) សម្ភារៈគាំទ្រ (ឯកសារភ្ជាប់ជាមួយ)

ឃ) អនុស្សរណៈ

ង) ឯកសារពាក់ព័ន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ

ច) ឯកសាររដ្ឋបាល ឬផ្នែកនីតិវិធី (សំណើសុំកែតម្រូវ បញ្ជីឯកសារ តារាងសំអាងផ្លូវច្បាប់)។

33. ឯកសាររបស់អង្គជំនុំជម្រះនីមួយៗ និងការិយាល័យសហចៅក្រមស៊ើបអង្កេតបន្ទាប់ពីការកំណត់ប្រភេទខាងលើ នឹងត្រូវចងក្រងតាមប្រភេទឯកសារមានដូចជា៖

ក) សាលក្រម សេចក្តីសម្រេច ដីកាបង្គាប់ និងដីកាកោះ

ខ) ភស្តុតាង

គ) សម្ភារៈគាំទ្រ (ឯកសារភ្ជាប់ជាមួយ)

ឃ) ចម្លើយជនសង្ស័យ

ង) ប្រតិចារឹក

ច) ដីកាចាត់ឱ្យស៊ើបសួរជំនួស

ឆ) ឯកសាររដ្ឋបាល ឬផ្នែកនីតិវិធី (សំណើសុំកែតម្រូវ សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងបញ្ជីឯកសារ)។

*២. ការពិនិត្យឯកសារ*

i. *សាលក្រម សេចក្តីសម្រេច ដីកាបង្គាប់ និងដីកាកោះរបស់អង្គជំនុំជម្រះ និងការិយាល័យសហចៅក្រមស៊ើបអង្កេត*

34. សាលក្រម សេចក្តីសម្រេច ដីកាបង្គាប់ និងដីកាកោះរបស់អង្គជំនុំជម្រះ និងការិយាល័យសហចៅក្រមស៊ើបអង្កេត នឹងត្រូវកែប្រែចំណាត់ថ្នាក់ លើកលែងតែមានបញ្ហាដែលតម្រូវឱ្យរក្សាសម្ងាត់ ឬសម្ងាត់បំផុតស្របតាមគោលការណ៍ទូទៅ។

35. ព័ត៌មានណាមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬសាក្សីដែលត្រូវបានការពារ ដូចជាឈ្មោះ អាសយដ្ឋានទំនាក់ទំនង ព័ត៌មានដែលបង្ហាញអត្តសញ្ញាណឯកជនដទៃទៀត នឹងត្រូវកោសលុប[62]។

[62] ដោយសារសហមេធាវីនាំមុខមានការព្រួយបារម្ភអំពីព័ត៌មានជនរងគ្រោះបង្ហាញអំពីហិង្សាផ្លូវភេទ ព័ត៌មានផ្ទាល់ខ្លួនផ្នែកវេជ្ជសាស្ត្រ បទពិសោធន៍ និងទិដ្ឋភាពស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារពាក់ព័ន្ធនឹងការធ្វើទារុណកម្ម រួមទាំងចម្លើយសារភាព និងប្រវត្តិរូបសង្ខេប និងការបង្ហាញឈ្មោះចារីដែលត្រូវបានចោទប្រកាន់ អង្គជំនុំជម្រះបង្គាប់ថា ព័ត៌មាននោះត្រូវកោសលុប។ ដូចបានសង្កេតខាងដើម មានភាពចាំបាច់ត្រូវថ្លឹងថ្លែងរវាងតម្រូវការក្នុងការរក្សាសម្ងាត់ និងតម្រូវការតម្លាភាព។ តបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាដែលថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សី រួមបញ្ចូលប្រតិចារឹក និងការថតជាសម្លេង គប្បីដាក់ជាសាធារណៈដើម្បីអត្ថប្រយោជន៍នៃការអប់រំ កេរដំណែល និងការកសាងសមត្ថភាព និងចំពោះព័ត៌មានទំនាក់ទំនងលម្អិត និងព័ត៌មានរសើបដទៃទៀតត្រូវស្ថិតក្រោមការកោសលុប និងការពិគ្រោះពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះបង្គាប់ថា ព័ត៌មានទាំងនោះត្រូវកោសលុប។

36. ដីកាកោះនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងនៅរក្សាចំណាត់ថ្នាក់សម្ងាត់ប្រសិនបើពុំមានការកោសលុប[63]។

37. ដីកាចាត់ឱ្យស៊ើបសួរជំនួសនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់ប្រសិនបើពុំមានការកោសលុប។

ii. *ប្រតិចារឹកនៃការស្តាប់ចម្លើយ និងសវនាការ*

38. ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញលើប្រតិចារឹកស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងមជ្ឈមណ្ឌល DC-Cam នឹងតម្រូវឱ្យមានការកោសលុបអាសយដ្ឋានទំនាក់ទំនង អត្តសញ្ញាណ ឬព័ត៌មានឯកជនដទៃទៀត។

39. ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញលើប្រតិចារឹកនៃសវនាការដែលត្រូវបានធ្វើឡើងដោយសម្ងាត់នឹងតម្រូវឱ្យមានការកែប្រែចំណាត់ឯកសារនេះទៅជាសាធារណៈដោយមានការកោសលុប។

iii. *សារណា ញត្តិ និងសំណើសុំលើអង្គសេចក្តីរបស់ភាគី*

40. សារណា ញត្តិ និងសំណើសុំលើអង្គសេចក្តីរបស់ភាគីនឹងត្រូវកែប្រែចំណាត់ថ្នាក់ លើកលែងតែមានបញ្ហាដែលតម្រូវឱ្យរក្សាការសម្ងាត់ ឬសម្ងាត់បំផុតស្របតាមគោលការណ៍ទូទៅ។ ជាឧទាហរណ៍ សំណើសុំទាក់ទងទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធចោល សំណើសុំពាក់ព័ន្ធទៅនឹងវិធានការការពារ និងឯកសារ និងព័ត៌មានដែលតម្រូវឱ្យមានវិធានការការពារនឹងត្រូវរក្សាចំណាត់ថ្នាក់ជាសម្ងាត់។

---

[63] អង្គជំនុំជម្រះទទួលយកអនុសាសន៍របស់សហព្រះរាជអាជ្ញាថា ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈនូវដីកាកោះជនជាប់ចោទក្នុងសំណុំរឿង ០០២ និង/ឬមេធាវីការពារក្តីរបស់ខ្លួនឱ្យចូលខ្លួនបឋម និងបន្តបន្ទាប់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ រួមទាំងសវនាការនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រមទាំងការចូលរួមសវនាការចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលរួមទាំងដីកាចាប់ខ្លួន។ ទោះជាយ៉ាងណាក្តី ដីកាកោះភាគច្រើននៅមុនការជំនុំជម្រះត្រូវបានបញ្ជូនទៅឱ្យសាក្សីសក្តានុពលសម្រាប់ការស្តាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត។ បើទោះបីជាបុគ្គលទាំងនេះក្រោយមកបានផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះក៏ដោយ ក៏ឯកសារទាំងនេះបានបង្ហាញអត្តសញ្ញាណបុគ្គលដែលបង្ហាញភាពឯកជននៅពេលសហការជាមួយកិច្ចស៊ើបសួរ។ សហព្រះរាជអាជ្ញាផ្តល់អនុសាសន៍ថា ដីកាកោះប្រភេទនេះនៅរក្សាចំណាត់ថ្នាក់សម្ងាត់។ បន្ទាប់ពីការពិនិត្យពេញលេញលើដីកាកោះ អង្គជំនុំជម្រះនឹងត្រូវកំណត់ព័ត៌មានរសើប និងបង្គាប់ឱ្យកោសលុប។

41. ព័ត៌មានរសើប បង្ហាញអត្តសញ្ញាណ ឬឯកជនពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬសាក្សីដែលត្រូវបានការពារ នឹងត្រូវកោសលុប។ ឧទាហរណ៍ ព័ត៌មានរសើបពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទ និងផ្នែកលើភេទ ព័ត៌មានផ្នែកវេជ្ជសាស្ត្ររបស់អ្នកដាក់ពាក្យបណ្ដឹង សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬព័ត៌មានដែលកំណត់អត្តសញ្ញាណចារីដែលត្រូវបានចោទប្រកាន់ ដែលត្រូវបានបង្ហាញឈ្មោះដោយដើមបណ្ដឹងរដ្ឋប្បវេណីដែលពុំត្រូវបានដាក់ចំណាត់ថ្នាក់សាធារណៈក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះ នឹងត្រូវកោសលុប។

iv. *ភស្តុតាង និងឯកសារគាំទ្រ*

42. ឯកសារភ្ជាប់ទៅនឹងសាលក្រម សេចក្ដីសម្រេច និងដីកាបង្គាប់របស់ អ.វ.ត.ក. អង្គជំនុំជម្រះ និងតុលាការដទៃទៀត ដែលជាសេចក្ដីដកស្រង់ នឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងឯកសារទាំងនេះមានជាសាធារណៈស្រាប់។

43. ឯកសារភ្ជាប់ទៅនឹងរបាយការណ៍នឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងឯកសារទាំងនេះមានជាសាធារណៈស្រាប់។

44. ឯកសារភ្ជាប់ទៅនឹងវិធានផ្ទៃក្នុង និងបទបញ្ជា នឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងឯកសារទាំងនេះមានជាសាធារណៈស្រាប់។

45. ឯកសារភ្ជាប់ទៅនឹងអត្ថបទសិក្សា សៀវភៅ អត្ថបទផ្សព្វផ្សាយ និងរបាយការណ៍វិភាគនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់ដើម្បីការពារសិទ្ធិអ្នកនិពន្ធលើកលែងឯកសារទាំងនេះមានជាសាធារណៈស្រាប់។

46. ក្នុងការការពារព័ត៌មានរសើប និងឯកជន តម្រូវឱ្យមានការកោសលុបសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវចម្លើយរបស់ជនសង្ស័យ និងភស្តុតាងជាសក្ខីកម្ម។

47. ឯកសាររបស់សាក្សីនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់។

ក) ឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យ

48. សេចក្ដីថ្លែងសាធារណៈ កំណត់ហេតុកិច្ចប្រជុំ ទូរលេខ របាយការណ៍ដែលរួមបញ្ចូលរបាយការណ៍បញ្ជាក់ទីតាំង របាយការណ៍ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ កំណត់ហេតុស្ដាប់

ចម្លើយនៃកិច្ចស៊ើបសួរ ទូរលេខ បញ្ជីឈ្មោះអ្នកជាប់ឃុំ ប្រវត្តិរូប ចម្លើយសារភាព និងអត្ថបទផ្សព្វផ្សាយជាឯកសារស្ថិតក្នុងចំណោមឯកសារសម័យកម្ពុជាប្រជាធិបេតយ្យ។

49. ឯកសារជាច្រើនពីសម័យកម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពជាសាធារណៈក្នុងសំណុំរឿងដទៃទៀត ឬលើប្រព័ន្ធអ៊ីនទ័រណែត។ ទោះជាយ៉ាងណាក្តី ឯកសារដែលមានព័ត៌មានរសើបដែលតម្រូវឱ្យមានការបន្តការការពារ ត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់ ដូចជា៖

ក) របាយការណ៍បញ្ជាក់ទីតាំង៖ តម្រូវឱ្យមានការកោសលុបដើម្បីការពារអត្តសញ្ញាណនៃប្រភពដែលបានផ្តល់តម្រុយនៃការស៊ើបសួរ ប៉ុន្តែពុំបានផ្តល់ការបញ្ជាក់ផ្លូវការ។

ខ) របាយការណ៍ស្តីពីដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលពាក្យសុំរបស់ខ្លួនអាចទទួលយកបាន៖ តម្រូវឱ្យមានការកោសលុបលើព័ត៌មានទំនាក់ទំនង និងព័ត៌មានឯកជន ឬរសើប។

គ) របាយការណ៍ស្តីពីដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលពុំត្រូវបានទទួលយកក្នុងសំណុំរឿង៖ ត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់។

ឃ) កំណត់ហេតុស្តាប់ចម្លើយនៃកិច្ចស៊ើបសួរ៖ ត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងមានការកោសលុប។

ង) បញ្ជីឈ្មោះអ្នកជាប់ឃុំដែលមានព័ត៌មានរសើប៖ ត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងមានការកោសលុប[64]។

ច) ប្រវត្តិរូប៖ ត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងមានការកោសលុប។

ឆ) ចម្លើយសារភាព៖ ត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងមានការកោសលុប។

---

[64] សហព្រះរាជអាជ្ញាគាំទ្រភាពស៊ីសង្វាក់គ្នានៃតម្លាភាពជាអតិបរមាជាមួយនឹង មុខងាររបស់តុលាការ និងថា នៅពេលបញ្ចប់សំណុំរឿង ឯកសារសម្ងាត់សេសសល់ត្រូវពិនិត្យឡើងវិញសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ។ សហព្រះរាជអាជ្ញាស្នើឡើងថា ដោយសារឯកសារទាំងនេះពុំមែនជាលទ្ធផលនៃការធ្វើទារុណកម្ម គប្បីដាក់ចំណាត់ថ្នាក់ទៅជាសាធារណៈ និងក្នុងករណីចាំបាច់ ដូចជាតម្រូវឱ្យមានវិធានការការពារ ឬការពារជនរងគ្រោះពីអំពើហិង្សាផ្លូវភេទ និងផ្អែកលើភេទគប្បីកោសលុបឈ្មោះជនរងគ្រោះ។ការិយាល័យរដ្ឋបាលស្នើថា គប្បីជាសាធារណៈ។

ជ) សៀវភៅកំណត់ហេតុ៖ ត្រូវដកសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយនៅមន្ទីរសន្តិសុខដែលរៀបរាប់លម្អិតអំពីខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកជាប់ឃុំ ដែលតាមការសន្មតទទួលបានតាមរយៈការធ្វើទារុណកម្ម ចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់លើកលែងមានការកោសលុប។

50. សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់នៅក្នុងប្រភេទនេះក្នុងឧបសម្ព័ន្ធ ក នៃសំណើសុំរបស់ខ្លួន។

ខ) ឯកសារពាក់ព័ន្ធទៅនឹងកិច្ចដំណើរការស៊ើបសួរ

51. ប្រភេទសំបុត្រខាងក្រោមនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់៖ របាយការណ៍អង្គភាពគាំពារសាក្សី និងអ្នកជំនាញ សំណើសុំជំនួយកិច្ចស៊ើបសួរការទំនាក់ទំនងស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង លិខិតធានា លិខិតមរណភាព លិខិតទាក់ទងទៅនឹងការប្រគល់ឯកសារដែលរៀបរាប់លម្អិតអំពីទីកន្លែងបុគ្គលទទួលលិខិតនោះ លិខិតទាក់ទងទៅនឹងបញ្ហាបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លិខិតទាក់ទងទៅនឹងការតំណាងផ្លូវច្បាប់នៃដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ លិខិតផ្ទេរសិទ្ធិដោយអាណត្តិ ការដកខ្លួនចេញពីកិច្ចដំណើរការនីតិវិធី ការផ្ទេរឯកសារចូលក្នុងសំណុំរឿង ០០៣ និង ០០៤ និងការជូនដំណឹងអំពីការកែប្រែឋានៈពីអ្នកប្តឹងទៅជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

52. រាល់ផែនទីទាំងអស់ក្នុងសំណុំរឿងនឹងត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ។

53. រូបថតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាក្សីដែលត្រូវបានការពារនឹងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់។

v. *អនុស្សរណៈ*

54. អនុស្សរណៈរបស់ភាគី អង្គភាពគាំពារជនរងគ្រោះ អង្គភាពគាំពារសាក្សីនឹងអ្នកជំនាញនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវធ្វើចំណាត់ថ្នាក់ និងរក្សាចំណាត់ថ្នាក់សម្ងាត់។

### vi. *ឯកសារទាក់ទងទៅនឹងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី*

55. ការដាក់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារពាក់ព័ន្ធទៅនឹងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នបំផុតដើម្បីការពារសន្តិសុខ និងសិទ្ធិឯកជនដើមបណ្តឹងរដ្ឋប្បវេណី។ គួរកត់សម្គាល់ តម្រូវឱ្យមានពេលវេលាជាច្រើនដើម្បីធ្វើការកោសលុបសម្រាប់ឯកសារបែបនេះប្រសិនបើមានដើម្បីអាចកែប្រែការដាក់ចំណាត់ថ្នាក់សម្ងាត់បច្ចុប្បន្ន។ លើកលែងមានការបញ្ជាក់ផ្សេង អង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ឯកសារនេះត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់។

### vii. *ឯកសាររដ្ឋបាល ឬផ្នែកនីតិវិធី*

56. ឯកសាររដ្ឋបាល ឬផ្នែកនីតិវិធីដូចជា បញ្ជីឯកសារ សំណើសុំកែតម្រូវ សំណើសុំការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងលិខិតបញ្ជាក់ស្តីពីការជំនួសឯកសារនឹងត្រូវដកចេញពីបញ្ជីឯកសារដែលត្រូវកែប្រែចំណាត់ថ្នាក់ និងត្រូវរក្សាចំណាត់ថ្នាក់សម្ងាត់។

## គ. <u>សេចក្តីសង្កេតចុងក្រោយ</u>

57. ដោយពិចារណាលើសារណារបស់ភាគី អង្គជំនុំជម្រះ និងអង្គភាពនៃ អ.វ.ត.ក. អង្គជំនុំជម្រះតុលាការកំពូលបន្ទាប់ពិនិត្យដោយប្រុងប្រយ័ត្នលើឯកសារដែលបានធ្វើចំណាត់ក្នុងសំណុំរឿង ០០២ ឃើញថាពុំតម្រូវឱ្យមានសេចក្តីសង្កេតបន្ថែមពីភាគី អង្គជំនុំជម្រះ និងអង្គភាពនៃ អ.វ.ត.ក. ឡើយ។

58. បន្ទាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេចបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវចេញដីកាបង្គាប់ក្នុងពេលសមស្របទៅអង្គភាពបណ្ណសារ (“RAU”) ជាមួយនឹងឧបសម្ព័ន្ធនៃបញ្ជីឯកសារដែលរៀបរាប់ឯកសារត្រូវកែប្រែចំណាត់ថ្នាក់។

59. ក្រោយពីការចេញសេចក្តីសម្រេចបច្ចុប្បន្ននេះ និងដីកាបង្គាប់ឱ្យធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅអង្គភាពបណ្ណសារ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យអង្គភាពបណ្ណសារបញ្ជូនឯកសារដែលបានកែប្រែចំណាត់នោះត្រឡប់មកវិញដើម្បីពិនិត្យ និងយល់ព្រមចុងក្រោយនៅមុនការជូនដំណឹងជាសាធារណៈនោះ។

## IV. ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះសម្រេច៖**

**អនុម័ត**សេចក្តីណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដូចបានរៀបរាប់ខាងលើ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**